# ការសំភាសន៍របស់អ្នកមីង មួង សុខំ

កៈ អ្នកដែរសំភាសន៍គេមាន ជាង ស៊ីអ៊ាវ ខៈ អ្នកដែរអោយគេសំភាសន៍មាន មួង សុខំ

## <u>ការសង្ខេបរបស់អ្នកមីង មួង សុខំ</u>

អ្នកមីង មួង សុខំ មានអាយុ62ឆ្នាំ នៅឆ្នាំ2018នេះ អ្នកមីង មួង សុខំ មានភេទ ស្រីអ្នកមីង មួង សុខំ មានទីលំនៅបច្ចុប្បន្ននៅ ភូមិរលាផ្អៀរ ស្រុកផ្អេរ ខេត្តកំពង់ឆ្នាំង។

កៈ ជាដំបូងខ្ញុំអរគុណច្រើនមីងដែរបានអោយខ្ញុំបានសំភាសន៍ពីប្រវត្តិរបស់មីង ហើយការសំភាសន៍នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចហាសមីងដែរមានឈ្មោះថា BYU ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរ ដើម្បីអោយកូនចៅជំនាន់ក្រោយៗអោយពួកគាត់បានស្គាល់ពីប្រវត្តិឪពុកម្តាយនឹងដូនតាចឹងហាសមីង ចឹងពេលដែរខ្ញុំបានសំភាសន៍មីងហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសមីង ហើយការសំភាសន៍មួយនេះខ្ញុំនឹងសំភាសន៍មីងដោយផ្ទាល់ចឹងហាសមីង បាទចឹងមីងយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរទេមីង?

ខៈ ដាក់ទៅមានអី

កៈ ចឹងសំរាប់ខ្ញុំជាអ្នកដែរសំភាសន៍មីងខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ាវ ហើយការសំភាសន៍នេះត្រូវបានធ្វើឡើងនៅថ្ងៃទី31 ខែ1 ឆ្នាំ2018 ហើការសំភាសន៍មួយនេះត្រូវធ្វើឡើងនៅភូមិ5 សង្កាត់ផ្សារថ្មូវ ខ័ណ្ឌចំការមន នៅរាជធានីភ្នំពេញ ចឹងសំរាប់មីងឈ្មោះពេញរបស់មីងមានឈ្មោះអីគេដែរមីង?

ខៈ ការខ្ញុំដាក់ឈ្មោះពេញខ្ញុំដាក់ឈ្មោះថា ផល្លី

កៈ ដែរត្រូវនឹងអត្តសញ្ញាណប័ណហាស?

ខៈ អត់ទេអានឹងខ្ញុំដាក់ពេលដែរនៅជំនាន់អាពតមកនឹង

កៈ ចុះឈ្មោះពេញរបស់មីងតែម្តងមានឈ្មោះអីគេដែរមីង?

ខៈ ខ្ញុំឈ្មោះ មួង សុខំ

កៈ ឈ្មោះមួង សុខំ ចុះមានឈ្មោះហៅក្រៅទេមីង?

ខៈ ឈ្មោះហៅក្រៅឈ្មោះផល្លី

កៈ អូ៎!ឈ្មោះផល្លីណាមីង ចុះកាលពីតូចមាននរណាគេហៅឈ្មោះមីងអីផ្សេងទៀតទេមីង?

ខៈ អត់ទេ

កៈ អត់ទេណាមីង ចុះមីងសព្វថ្ងៃមីងមានអាយុប៉ុន្មានដែរទៅមីង?

ខៈ ខ្ញុំអាយុច្រើនដែរហើយខ្ញុំអាយុ62ឆ្នាំហើយនឹង

កៈ អូ៎!មីងអាយុ62ឆ្នាំណាមីង ចុះមីងកើតនៅថ្ងៃខែឆ្នាំណាមីងមានចងចាំទេ?

ខៈ ខ្ញុំអត់ចាំឆ្នាំបារាំងទេ ខ្ញុំចាំតែឆ្នាំខ្មែរនឹង

កៈ ចុះនៅឆ្នាំខ្មែរមីងមានឆ្នាំអីគេដែរមីង?

ខៈ ខ្ញុំកើតនៅឆ្នាំវក

កៈ មីងកើតនៅឆ្នាំវកណាមីង ចាំមួយភ្លេតមីង?

ខៈ ខ្ញុំកើតនៅឆ្នាំវក ខែស្រាព

កៈ អូ៎! ចឹងមីងកើតនៅឆ្នាំ1956 មីង

ខៈ នឹងហើយត្រូវ

កៈ ចឹងសំរាប់ទីតាំងដែរកន្លែងកំណើតដែរមីងកើត តើមីងកើតនៅណាដែរមីង?

ខៈ ខ្ញុំកើតនៅស្រុកកំពង់ឆ្នាំង

កៈ ចុះកើតនៅភូមិអី ឃុំអីដែរមីង?

ខៈ នៅភូមិរលាផ្អៀរ ស្រុកផ្អេរ

កៈ នៅស្រុកផ្អេរ ខេត្តកំពង់ឆ្នាំងណាមីង?

ខៈ ចាំ!នឹងហើយ

កៈ ចុះមីងមានបងប្អូនប៉ុន្មានដែរមីង?

ខ៖ អត់ទេស្លាប់បាត់អស់ហើយនៅតែខ្ញុំម្នាក់ឯងនឹង

ក៖ ប៉ុន្តែកាលពីពួកគាត់នៅរស់មីងមានប៉ុន្មាននាក់ដែរទៅមីង?

ខ៖ មានតែ2នាក់ទេប៉ុន្តែគាត់ក៏ស្លាប់បាត់អស់ដែរនឹងហាស

ក៖ បាទមីងចឹងមីងជាកូនពៅ រឺមួយក៏ជាកូនបងដែរមីង?

ខ៖ ចាំ!កូនពៅនឹង

ក៖ អូ៎!មីងជាកូនពៅ ចុះបងរបស់មីង តើមីងអាចប្រាប់ឈ្មោះពួកគាត់ដែរបានទេមីង?

ខ៖ គាត់មានឈ្មោះ មួង វណ្ណាត ប៉ុន្តែគាត់ស្លាប់បាត់យូរដែរហើយនឹង

ក៖ អូ៎! បាទមីង ចុះកាលពីមីងនៅក្មេងតើមីង
មានធ្លាប់មានអនុស្សាវរីយ៍អីជាមួយគាត់កាលពីមីងនៅក្មេងទេមីង?

ខ៖ អត់មានធ្វើអីជាមួយគាត់ទេ អត់មានអនុស្សាវរីយ៍កំសត់កំរអីជាមួយគាត់ទេ
អត់ដែរមានអីផងនឹង
ខ្ញុំបានបែកគ្នាកាលពីសម័យអាពតនឹងមកក៏បានបែកគ្នារហូតទៅចឹងទៅណាស់

ក៖ អូ៎!បាទមីងចុះកាលពីនៅក្មេង តើមីងមានចូលចិត្តធ្វើអីជាមួយប្អូនរបស់មីងដែរមីង?

ខ៖ ខ្ញុំមិនបានធ្វើអីគេទេប៉ា ម៉ាក់របស់ខ្ញុំអោយខ្ញុំនៅតែផ្ទះ ប៉ុន្តែខ្ញុំចូលចិត្តតែចាក់អាវ
ចាក់មួក ចាក់កន្សែងអីចឹងទៅណាស់

ក៖ ប៉ុន្តែមានធ្លាប់មានលេងឡឹកបាយឡអីជាមួយបងប្អូនរបស់មីងដែរទេមីង?

ខ៖ អត់ចេះលេងទេ

ក៖ សូម្បីតែទៅស្រែក៏អត់ដែរណាមីង?

ខ៖ ដោយសារតែប៉ារបស់ខ្ញុំគាត់បើកឡានតាមខេត្តចឹងខ្ញុំអត់ចេះធ្វើអីទេនៅតែផ្ទះនឹង
រហូតដល់ពេលដែរាពតចូលមកក៏យើងបែកគ្នាត្រឹមនឹងទៅ

ក៖ ចឹងមានន័យថាបងរបស់មីងគាត់ស្លាប់ហើយណាមីង?

ខ៖ ស្លាប់យូរដែរហើយនឹង ស្លាប់តាំងពីសង្គមមកម្ល៉េសហើយនឹង

ក៖ អូ៎! បាទមីងចុះម្តាយរបស់មីងគាត់មានឈ្មោះអីគេដែរមីង?

ខ៖ ម្តាយរបស់ខ្ញុំគាត់មានឈ្មោះលី នួន

កៈ គាត់អាយុប៉ុន្មានដែរមីង?

ខៈ គាត់ស្លាប់នៅអាយុ73ឆ្នាំ

កៈ ប៉ុន្តែគាត់ស្លាប់យូរនៅមីង?

ខៈ គាត់ស្លាប់យូរហើយ គាត់ស្លាប់នៅអាយុ73ឆ្នាំ គាត់ស្លាប់នៅពេលដែរអន្ទតាក់ចូលមកនឹង

កៈ នៅពេលដែរអន្ទតាក់ហោសមីង?

ខៈ ពេលដែរអន្ទតាក់ចូលភ្លាម គាត់ស្លាប់ភ្លាមនឹង

កៈ អន្ទតាក់នៅឆ្នាំណាដែរមីង?

ខៈ ដូចជានៅឆ្នាំបើមិន82 -83ទេនេះ

កៈ គាត់នៅឆ្នាំ83ណាមីង ចឹងវាប្រហែលជា35ឆ្នាំហើយណាមីង?

ខៈ នឹងហើយ

កៈ គាត់អាយុ73ឆ្នាំណាមីង?

ខៈ ចាំគាត់ស្លាប់នៅអាយុ73ឆ្នាំនឹង

កៈ អាយុ73បូកនឹង35ចឹងគាត់អាយុ108ឆ្នាំ?

ខៈ ចាំនឹងហើយ

កៈ ចឹងគាត់អាយុ108ឆ្នាំ ចឹងសំរាប់គាត់កើតនៅឆ្នាំណាមីងមានឹងទេ?

ខៈ អត់ដឹងទេ ដូចជាខ្ញុំចាំគាត់មិនសូវច្បាស់ដែរកើតនៅឆ្នាំមមែ ហើយគាត់កើតនៅខែជេត

កៈ ចឹងហោសមីងចឹងគាត់កើតនៅឆ្នាំ1910មីង?

ខៈ ចាចឹងហើយនឹង

កៈ ប៉ុន្តែទីកន្លែងកំណើតរបស់គាត់កើតនៅនាមីងមានដឹងទេមីង?

ខៈ គាត់នៅស្រុកកំពង់ហ្លួង

កៈ អូ!នៅស្រុកកំពង់ហ្លួង នៅខេត្តកណ្តាលយើងនឹងហោសមីង?

ខៈ នឹងហើយនៅខេត្តកណ្តាលយើងនឹង

កៈ  បាទមីង ចុះឪពុករបស់មីងគាត់មានឈ្មោះអីគេដែរមីង?

ខៈ  គាត់មានឈ្មោះ មួង សុខ

កៈ  ចុះគាត់អាយុប៉ុន្មានដែរមីង?

ខៈ  ខ្មោចប៉ារបស់ខ្ញុំ គាត់ប្អូនរបស់ខ្មោចម៉ែរបស់ខ្ញុំ6ឆ្នាំនឹង
ប៉ារបស់ខ្ញុំគាត់ស្លាប់នៅអាយុ56ឆ្នាំនៅសម័យអាពតចឹងហាស

កៈ  អូ៎!បាទមីង

ខៈ  គាត់ស្លាប់នៅឆ្នាំ1970គាត់បានស្លាប់បាត់ទៅ

កៈ  ចឹងគាត់ប្អូន6ឆ្នាំណាមីង ចឹងគាត់អាយុ102ឆ្នាំចឹងគាត់កើតនៅឆ្នាំ1916មីង?

ខៈ ចា៎!នឹងហើយ

កៈ  ចុះគាត់កើតនៅណាដែរមីង?

ខៈ  គាត់កើតនៅស្រុកកំពង់ឆ្នាំង

កៈ  នៅកំពង់ឆ្នាំងដែរណាមីង
ចុះឪពុករបស់មីងគាត់ធ្វើអីកេសំរាប់ចិញ្ចឹមជីវិតដែរមីងកាលពីគាត់នៅរស់ហាស?

ខៈ  គាត់បើកឡានសំរាប់រាប់ហាស គាត់បើកនៅកំពង់ឆ្នាំង
ដូចថាសំរាប់នរណាគេចេញចូលគាត់បើកឡានអោយគេចឹងហាស

កៈ  ចុះគាត់ចាមនុស្សបែបណាដែរមីង គាត់ស្លូត រឺមួយក៏កាច់ដែរមីង?

ខៈ  គាត់ដូចថាគាត់ជាមនុស្សដែរមឹងម៉ាត់តែម្តងនឹងហាស គាត់មិនចេះពិសារស្រា
លេងបៀរអីគាត់មិនចេះទេ

កៈ  ប៉ុន្តែកាលពីគាត់នៅជាមួយកូនៗ
នឹងនៅជាមួយមីងតើគាត់កាច់រឺមួយក៏ស្លូតដែរដាក់កូនចៅចឹងហាសមីង?

ខៈ  អត់ទេគាត់ចំណាប់គាត់អត់កាច់ដូចយើងទេ
គ្រាន់តែគាត់ប្រាប់យើងថាកូនមិនត្រូវដើរលេងផ្ទះគេ
កូនមិនត្រូវនិយាយដើមគេគឺអត់បានចឹងខ្ញុំអត់ដែរបានដើរលេងផ្ទះគេទេ
ហើយខ្ញុំមិនដែរបានទៅលេងឡឹកបាយឡនៅផ្ទះគេទេ

កៈ  អូ៎!បាទមីង

ខ៖ នឹងចឹងហើយនឹងណា

ក៖ ចុះម្ដាយរបស់មីងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរមីងដែរ?

ខ៖ គាត់នៅផ្ទះដូចខ្ញុំចឹងដែរនឹង
ពីព្រោះតែប៉ារបស់ខ្ញុំគាត់ជាអ្នកដែរបើកឡានតាមរងខេត្តចឹង
ឯម៉ែគាត់នៅមើលកូនដូចគ្នានឹង

ក៖ បាទមីងចុះគាត់កាច់រឺមួយក៏ស្លូតដែរមីង?
ខ៖ គាត់មែនជាអ្នកកាច់ដែរទេ និយាយទៅគាត់មិនមែនចេះកាច់អីទេ

ក៖ បាទៗមីងចុះ មីងមានចងចាំសាច់រឿងអីដែរមីងនៅជាមួយម្ដាយឪពុករបស់មីងទេ?

ខ៖ អត់ទេ អត់ចងចាំទេគ្រានតែខ្ញុំដឹងថាឪពុកម្ដាយរបស់ខ្ញុំគាត់ល្អគ្រាប់10តែម្ដងនឹង

ក៖ អូ៎! ចឹងហោសមីង?

ខ៖ ចាំគាត់មិនដែរអោយពួកយើងលំបាកទេ
លំបាកតែពេលដែរកាលពីអាពតបានចូលមកនោះទេនឹងហាស

ក៖ អូ៎!បាទមីងចឹងហោស?

ខ៖
ប៉ុន្តែពេលដែរអាពតចូលមកគាត់ប្រាប់ពួកយើងថាកូនអើយអាពតចូលមកហើយនឹងហាស
គាត់ថាកូនឯងចាំមើលណាតិចទៀតយើងហូបបាយរួមនឹងហាស
ហើយធ្វើការអីក៏ធ្វើរួមដែរនឹងហាស

ក៖ អូ៎!គាត់ដឹងណាមីង?

ខ៖ ខ្ញុំបានប្រកែកជាមួយឪពុករបស់ខ្ញុំថាខ្ញុំមានតែម្នាក់ឯងធ្លាប់តែលំបាក
តែបើប្រទេសគេសន្តិភាពចឹង យើងស្រួលហើយខ្ញិលដាំបាយខ្លួនឯងនឹងហាស

ក៖ អូ៎មីងអត់ដឹងទេណាមីង?

ខ៖ ហើយប៉ារបស់ខ្ញុំគាត់ថាមិនមែនទេកូនហាស
នេះគេហៅថាគុម្មុមនីសយ៍កូនឯងចាំទុកហាសកូនណា
ហើយដល់ពេលដែរខ្ញុំមើលហើយពិនិត្យវាទៅនឹងតាមដានវាទៅវាចឹងមែននឹងហាស

ក៖ បាទមីងចឹងហោសមីង?

ខ៖  ចឹងវារស់ដោយការលំបាក ខ្ញុំលំបាកនឹងការចូលអាពតភ្លាមនឹងខ្ញុំលំបាកហាស ដូចថាយើងធ្លាប់រស់នៅរស់ខេត្តចឹងទៅ យើងអត់ដែរស្គាល់ដើមស្រូវ រឺក៏វាលស្រែអីចឹងហាស យើងរស់នៅតែនៅលើផ្ទះ ហើយខ្ញុំវេទនាណាស់ ខ្ញុំរស់នៅតែនៅលើផ្ទះនឹងឯង

ក៖  អូ៎!ត្រូវហើយមីង?

ខ៖  ខ្ញុំមិនដឹងថាធ្វើរបៀបយ៉ាងម៉េចដែរ អោយកើតដូចគេចឹងហាសណា ចាំ ហើយគេបញ្ជាយើងអោយុកាលណុងគេបុករណ្ដៅដាក់អោយពេញៗចឹងទៅណា ហើយដល់ពេលណុងគេដកហើយគេអោយយើងមកបំបែកស្នូងហាស

ក៖  បាទមីងវាមិនស្រួលទេណាមីង?

ខ៖  ខ្ញុំអត់ចេះដកដូចគេ ខ្ញុំដកមួយគុម្ពមកយកមកវៃបែកអស់ហើយជើងរបស់ខ្ញុំនឹង ហើយប៉ារបស់ខ្ញុំគាត់ថា បងប្អូនអើយជួយប្រាប់វាផងវាមិនចេះទេនឹងហាសខ្ញុំភ័យហាស ខ្ញុំគិតថាខ្ញុំហើយដែរគេយកទៅវៃចោលមុនគេនឹង ខ្ញុំអត់ចេះអីទាំងអស់ចឹងហាស

ក៖  អូ៎!បាទៗមីង

ខ៖  តែដល់ពេលណុងក៏ចេះតែហាត់ពុតលុតជំតាមគេទៅក៏អត់អីដែរនឹង

ក៖  ប៉ុន្តែមីងអាចធ្វើបានដូចគេ?

ខ៖  ចាំ!ខ្ញុំធ្វើបានដូចគេដែរនឹង ចឹងបានថាការវេទនានឹងបានវាវេទនានឹងហាស

ក៖  ចុះឪពុកម្ដាយរបស់មីងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងទៅមីងទេ?

ខ៖  ចាំ!ធ្លាប់តា រឿងប្រវត្តិគាត់មិនដែរបានប្រាប់ទេនឹង គាត់គ្រាន់តែនិយាយប្រាប់យើងថាគាតដឹងតែប្រវត្តិគាត់ដែរពេលដែរកាត់ធ្វើការងារចឹង គេប្រាប់គាត់គាតដឹងតែអានឹង គាត់ដឹងតែនៅពលពតនឹងគាត់ដឹងតែពិបាកនឹងហាស

ក៖  ចុះយាយតាខាងឪពុកមីងមានស្គាល់ឈ្មោះគាត់ដែរទេមីង?

ខ៖
ខ្ញុំកើតអត់ទាន់ទេតារបស់ខ្ញុំគាត់ស្លាប់តាំងពីប៉ារបស់ខ្ញុំគាត់អាយុ13ឆ្នាំនឹងមកតាំងពីឪពុករបស់ខ្ញុំគាត់នៅតូចៗមក

ក៖  ប៉ុន្តែឈ្មោះអីក៏មីងមិនចាំដែរណាមីង?

ខ៖  ខ្ញុំអត់ចាំទេ

កៈ ចុះយាយតាខាងម្តាយមីងមានចងចាំឈ្មោះគាត់ដែរទេ?

ខៈ យាយតាខាងម្តាយក៏គាត់ស្លាប់តាំងពីក្មេងៗនឹងដែរ

កៈ អូ៎! ចុះមីងមករស់នៅទីក្រុងភ្នំពេញនឹងយូរនៅមីង?

ខៈ មកនៅនេះហោស ខ្ញុំមិនទាន់បានមកនៅបានយូរប៉ុន្មានដែរទេ ខ្ញុំទើបតែមកនៅបានប្រហែលជា2ឆ្នាំនឹងទេ

កៈ អូ៎! ចុះពីមុននឹងមីងនៅណាដែរទៅមីង?

ខៈ ពីមុននឹងខ្ញុំនៅជិតព្រំដែននៅជិតប៉ោយប៉ែតនោះ

កៈ អូ៎!បាទមីងចុះមីងមានសាច់ញ្ញាតិណាដែររស់នៅក្រៅពីប្រទេសខ្មែរដែរទេមីង?

ខៈ ចា៎! ខ្ញុំអត់មានទេ

កៈ អូ៎!បាទមីងចុះស្វាមីរបស់មីងគាត់មានឈ្មោះអីគេដែរមីង?

ខៈ គាត់មានឈ្មោះ សេង សាន តែគាតស្លលប់ដែរហើយនឹង

កៈ អូ! ប៉ុន្តែមីងមានចងចាំថ្ងៃដែរមីងបានរបអាពាហ៍ពិពាហ៍ជាមួយគាត់ដែរទេមីង?

ខៈ ខ្ញុំអតចងចាំដែរនឹងហាស

កៈ ប៉ុន្តែកូនធំរបស់មីងគាត់អាយុប៉ុន្មានដែរទៅមីង?

ខៈ ខ្ញុំច្បងរបស់ខ្ញុំនឹងអាយុ31ឆ្នាំហើយនឹង

កៈ អាយុ31ឆ្នាំ ចុះពេលដែរមីងការហើយមីងមានកូនតែម្តងរឺក៏យ៉ាងម៉េចដែរមីង?

ខៈ ខ្ញុំបានគាត់រយះពេលតែមួយឆ្នាំខ្ញុំក៏មានកូនទៅ

កៈ បាទមីងចឹងកូនរបស់អាយុ31ឆ្នាំ ចឹងមីងការនៅឆ្នាំ1987ហាសមីង?

ខៈ ចា៎!នឹងហើយ

កៈ ចឹងដូចជាមីងគិតថានៅពេលដែរមីងរៀបអាពាហ៍ពិពាហ៍គិតថាមីងជាអ្នករៀបចំរៀបដោយចិត្តឯងរឺក៏ឪពុកម្តាយជាអ្នករៀបចំដែរមីង?

ខៈ និយាយទៅខ្ញុំនិយាយថាប្តីរបស់ខ្ញុំនេះអាពតជាអ្នករៀបចំអោយទេ ខ្ញុំមិនបានរៀបចំអោយទេ ម្តាយឪពុករបស់ខ្ញុំមិនបានដឹងទេ

ហើយកាលពីមុនក៏មិនបានដឹងអត់បានស្រលាញ់គ្នាអីគេដែរនឹង
តែអាពតគេមកចាប់យើងរៀបចឹងហាស

ក៖ អ៊ូ!បាទមីងចុះពេលដែររៀបនឹងដូចជាមានជាចំនួនរីបណ្ណាការអីទេមីង?

ខ៖ ទេអត់មានទេគេចាប់ដៃនឹង គេចាប់ម្តងជិត10គូរចឹងហាសណា

ក៖ ចុះអត់មានអីទៀតទេ?

ខ៖ អត់មានទេ

ក៖ ចុះដូចជាពេលណាដែរបងស្គាល់ប្តីរបស់បង
ហើយនឹងស្រលាញ់គ្នានៅពេលណាដែរបង ?

ខ៖ អត់មានទេ

ក៖ ដល់គេចាប់ៗតែម្តងហោសមីង?

ខ៖
ដូចថាគេឃើញអូនឯងធ្វើការចឹងនឹងពូអូនឯងចឹងគេត្រូវតែចាប់រៀបយើងគេបានប្រាប់ថា
ថ្ងៃទី17មេសា យើងត្រូវរៀបខ្លួនគេយកខោអាវ មកចែកអោយយើងចឹងហាស
នឹងកន្សែងក្រហមហើយយើងយកទៅ

ក៖ អ៊ូ!គេធ្វើចឹងហោសមីង?

ខ៖ គេប្តេជ្ញាតែម្នាក់ចឹងបានទាំងអស់គ្នាហើយនឹង

ក៖ ចុះមីងចេះអាន រឺក៏ចេះសរសេរអក្សរខ្មែរបានល្អប៉ុណ្ណាដែរមីង?

ខ៖ អត់ទេ អត់ចេះទេ

ក៖ មីងអត់ដែរបានចូលរៀនទេណមីង?

ខ៖ ចា៎! អត់បានទេ

ក៖ ចុះភាសាអីផ្សេងក្រៅពីភាសាខ្មែរមីងមានចេះទេ?

ខ៖ អត់ចេះទេ

ក៖ អត់ចេះដែរណមីង ចុះមីងធ្លាប់មានមិត្តភក្តិណាដែរធំធាត់មកជាមួយគ្នាទេមីង?

ខ៖ អត់ទេ

កៈ អត់ដែរមានមិត្តភក្តិទេណាមីង?

ខៈ ចា៎!!អត់មានទេ

កៈ ចុះមីងធ្លាប់ទៅធ្វើការនៅវាលស្រែទេមីង?

ខៈ ខ្ញុំធ្លាប់ទៅធ្វើការនៅវាលស្រែអី ដូចជាច្រូចស្រូវអីខ្ញុំធ្លាប់តា

កៈ ប៉ុន្តែពេលណុងនៅជំនាន់ណាដែរមីង?

ខៈ យើងនៅដូចថាខ្ញុំនៅអាយុតិចទើបតែអាយុ50ឆ្នាំអីចឹង យើងច្រូចអីចឹងហាសណា

កៈ បាទចឹងហោសមីង?

ខៈ មានតែដល់ពេលសម័យឪឥឡូវ អត់បានធ្វើអីទេ

កៈ ប៉ុន្តែមីងបានធ្វើអីគេខ្លះនៅស្រែនឹងហោសមីង?

ខៈ អត់ានធ្វើអីគេទេមានតែយើងច្រូចស្រូវនឹង ធ្វើចំការ
ស៊ីឈ្នួលកាច់ពោតអីចឹងហាសណា

កៈ បាទៗៗមីង! ចុះមីងមានធ្លាប់បានធ្វើការងារអីគេខ្លះនៅក្នុងជីវិតរបស់មីងដែរមីង?

ខៈ ខ្ញុំគ្មានធ្វើការអីគេទេ ខ្ញុំពេលដែរខ្ញុំបានប្តីមកពេលដែរឈបពីណុងមក
ខ្ញុំបានលក់ឥវ៉ាន់ចាប់ហ្វឹយ ចឹងទៅណា

កៈ អ៎ូ!បាទមីងចុះមីងគិតថាជីវិតរបស់មីងមានការផ្លាស់ប្តូរអីគេខ្លះដែរមីង?

ខៈ មានការផ្លាស់ប្តូរដែរ ប៉ុន្តែដល់ពេលដែរអត់ពីគ្រួសារយើងទៅ
យើងដូចជាគ្រួសាររបស់យើងកណ្តោចកណ្តែងចឹងហាស វាអត់មានអ្នកទីពឹងចឹង
ទៅទីពឹងតែកូនចឹងហាសណា

កៈ បាទមីង! ចុះមីងគិតថាមីងចូលចិត្តពិសារម្ហូបអីគេដែរចឹងហាសមីង?

ខៈ ខ្ញុំមិនរើសទេអូន ស្អីក៏ខ្ញុំញ៉ាំបានដែរនឹង

កៈ អត់ទេ ដែរកិតថាភាគច្រើនមីងចូលចិត្តញ៉ាំតែម្តងហាស

ខៈ ចា៎!ដូចជាស្លម្ជូរ

កៈ ហើយមីងនឹកឃើញចង់ញ៉ាំវាតែម្តងហាសមីង?

ខ៖ វីក៏បុកទឹកគ្រឿងអីចឹងហាសណា តាមចំណូលរបស់យើងចឹងទៅណា ចាំ!អត់មានរើសអីច្រើនទេខ្ញុំនោះ

ក៖ ចុះល្បែងប្រជាប្រិយ៍ដែរមីងគិតថាមីងចូលចិត្តលេងតាំងពីក្មេងរហូតមកដល់ពេលនេះហាសមីង?

ខ៖ អត់ចេះទេ

ក៖ អូ៎! មីងអត់ចេះលេងដណ្តើមស្លឹកឈើទេណាមីង?

ខ៖ អត់ចេះទេក្មួយ អត់ចេះលេងតែម្តងនឹង ចេះតែមើលគេមួយភ្លែត កាលពីនៅក្មេងទេ

ក៖ ចុះមីងចេះច្រៀងទេមីង?

ខ៖ ចាំ! អត់ចេះទេ

ក៖ ចុះមីងចូលចិត្តស្តាប់បទចំរៀងទេមីង?

ខ៖ ចូលចិត្តស្តាប់ដែរតា

ក៖ ចុះលក្ខណះថាជាបទសម័យរឺមួយបទបុរាណដែរមីង?

ខ៖ បទបុរាណចឹងទៅ បទស៊ិនស៊ីសាម៉ុតចឹងទៅ

ក៖ ចុះមាននរណានៅក្នុងក្រុមគ្រួសាររបស់មីង នឹងចេះលេងឧបករណ៍ភ្លេងទេមីង ទាងបងប្អូន ទាំងកូនចៅអីចឹងហាស ទាំងភ្លេងខ្មែរ ទាំងក្មេងសៀមដែរ?

ខ៖ អត់មានទេ

ក៖ អូ៎បាទ! ចុះផ្ទះរបស់មីងមានលក្ខណះបែបណាតាំងពីក្មេងរហូតដល់ពេលនេះបែបណាដែរមីង ពីក្មួយផ្ទះម៉េច ហើយតឡូវផ្ទះម៉េច?

ខ៖ យើងពីដើមផ្ទះរបស់យើងវារៀងធំដែរនឹង ដល់ពេលដែរធំមកយើងមិនដែរមានផ្ទះនៅខ្លួនឯងទេ យើងដើរតែជួលគេទេនឹងហាស

ក៖ កាលពីមុនមីងមានផ្ទះនឹង នរណាគេជាអ្នកសាងសងផ្ទះមួយនឹងដែរមីង?

ខ៖ ឪពុកម្តាយរបស់ខ្ញុំជាអ្នកសាងសង

ក៖ អូ៎!ឪពុកម្តាយមីងគាត់ចេះធ្វើផ្ទះហោសមីង?

ខ៖ ទេគាត់អ្នកធ្វើផ្ទះអោយខ្ញុំនៅតាំងពីដើមមកម្ល៉េស អត់ដឹងថានរណាគេជាអ្នកធ្វើទេ តែដល់ពេលដែរបានប្ដីទៅប្ដីគេជាអ្នកធ្វើអោយ

ក៖ អូ៎!ប្ដីរបស់មីងគាត់ចេះធ្វើផ្ទះណាមីង?

ខ៖ ចា៎!គាត់ចេះធ្វើតា

ក៖ គាតចេះធ្វើមកពីណាគេដែរមីង?

ខ៖ គាត់ចេះខ្លួនគាត់នឹង គាត់ចេះដាក់លាន់ត្រី អន្ទង់នឹងបង់សំណាញ់អីចឹងទៅ

ក៖ អូ៎!ចឹងហោសមីង?

ខ៖ ដល់ពេលចឹងរកមុខរបរតាមគាត់ចឹងទៅ

ក៖ ចុះមីងជំនាន់អីដែរមីងចេះស្ទាត់ជំនាញ់ហាស?

ខ៖ ខ្ញុំជំនាញស្ទាត់ជំនាញជាងគេគឺចាក់ខោអាវនឹងហើយ ដែរខ្ញុំស្ទាត់ជាងគេនឹង

ក៖ មីថងចេះចាក់ខោអាវណាមីង?

ខ៖ ចា៎!ចេះចាក់ខោអាវ ចាក់មួកអីចឹងទៅ

ក៖ ចុះម្ដាយឪពុករបស់មីងគាត់ធ្លាប់បង្រៀនពីជំនាញអីទៅមីងទេ?

ខ៖ អត់ទេ

ក៖ អត់ទេណាមីង ចុះដូចជាជំនាញវេញវល្លិ៍ កូរស្ករ ធ្វើផ្ដៅ ធ្វើជាកន្ទេល ធ្វើជាស្មឹមួយមីងចេះទេ?

ខ៖ អត់ទេ បើអោយខ្ញុំធ្វើអីមួយខ្ញុំចេះតែធរើបើអោយខ្ញុំបិទខ្ញុំមិនចេះទេ

ក៖

អូ៎!បាទមីងចុះមីងអាចប្រាប់ខ្ញុំបានទេថាពេលណាដែរមីងគិតថាជាពេលដែរលំបាកជាងគេនៅក្នុងជីវិតរបស់មីងហាស?

ខ៖ គឺសព្វថ្ងៃនេះឯងដែរធ្វើខ្ញុំបានជួបការលំបាកនឹង ខ្ញុំលំបាកតែខ្ញុំឈឺច្រើន ហើយលំបាកមួយទៀតនឹងគឺ អត់ពីប្ដីទៅយើងអត់មានអ្នកទីពឹង កាលពីដើមចឹងខ្ញុំមិនសូវដឹងពីកាលលំបាកទេ

ក៖ បាទមីងចឹងមានអីទៀតទេ?

ខ៖ នឹងហើយមានបញ្ហាអីប្ដីរបស់ខ្ញុំគាត់ជាអ្នករាប់រងចឹងហាស

ក៖ អ្ហ៎!ចឹងណាមីង?

ខ៖ ដល់សព្វថ្ងៃខ្ញុំមានតែកូនមួយទេ ជាអ្នកចិញ្ចឹមយើងចឹងទៅ
យើងក៏ពិបាកចឹងហាសពេលដែរឈឺជា សព្វថ្ងៃនឹងជំងឺគ្រប់មុខទាំងអស់នឹង
ប៉ះណាវាឈឺតាមអាឆ្អឹងអីចឹងទៅណា

ក៖ អ្ហ៎!ជំងឺរបស់មីងហោសមីង?

ខ៖ នឹងហើយដូចថារលោកសន្លាកអីចឹងទៅ យើងធ្វើទុករហូតចឹងទៅណា

ក៖ បាទមីងបាទ

ខ៖
ដូចថាប៉ុន្មានខែមុនអីចឹងទៅវាលើសឈាមនេះហើយជាការលំបាករបស់យើងអីចឹងទៅណា ចឹងបានកូនៗគេមិនអោយធ្វើអីគេមិនអោយពិបាកអីចឹងហាស
កូនថាម៉ែឯងនៅទ្រាំទ្រទៅ ហើយខ្ញុំថាសុខភាពខ្ញុំវាមិនសូវល្អទេ

ក៖ ចុះកាលពីនៅក្មេងមីងគិតថាមីងលំបាកអីគេដែរខ្លះដែរមីង?

ខ៖ ខ្ញុំមិនដែរលំបាកទេពីក្មេងមកគឺខ្ញុំមិនដែរស្គាល់ការលំបាកទេ
ចាប់ផ្តើមចេញពីអាពតទៅខ្ញុំចាប់ផ្តើមស្គាល់ការលំបាកហើយនឹង
ខ្ញុំគឹកថារកដោយខ្លួនឯងឪពុកម្តាយគាត់ស្លាប់ចោលអស់ គ្មានអ្នកទីពឹងទេ
ខ្ញុំទីពឹងតែប្តីនឹងខ្លួនឯងតែប៉ុណ្ណឹងឯង

ក៖ អ្ហ៎!បាទមីង?

ខ៖ ទោះបានហូបរឺមិនបានហូបនឹងតែ2នាក់យើងនឹង

ក៖ អ្ហ៎!បាទមីងបាទ?

ខ៖ បើកាលពីក្មេងខ្ញុំមិនដែរស្គាល់ថាការអត់របៀបយ៉ាងម៉េចទេ
ដូចថាម៉ែថាអោយទៅនេះអោយទៅនោះអោយធ្វើការគឺគាត់មិនអោយទៅណាទេ
នៅតែនៅក្នុងផ្ទះទៅ មានតែប៉ុណ្ណឹងគាត់អោយយើងចេញមានការលំបាកអីអត់ទេ

ក៖ បាទមីងចុះសំរាប់ជំនាន់ពលពតគេអោយមីងធ្វើអីគេទៅមីង?

ខ៖ គេអោយយើងស្ទូងស្រូវ គេអោយយើងបេះកប៉ាស គេអោយយើងបេះសណ្តែក
គេអោយយើងដកដំឡូងគរអីចឹងទៅ
គេប្រើយើងគ្រប់មុខទៅអោយតែគេប្រើយើងអោយទៅ គឺយើងទៅធ្វើទាំងអស់នឹងណាស់

កៈ ប៉ុន្តែដូចជាមីងធ្វើនឹងតើមីងធ្វើនៅណាវិញទៅមីង?

ខៈ កាលពីខ្ញុំធ្វើនឹងគឺខ្ញុំធ្វើនៅអន្លង់វែរ

កៈ អន្លង់វែរនឹងនៅណាដែរមីង?

ខៈ នៅថនសាលានៅជិតប៉ៃលិនវិញនឹង

កៈ អូ៎!នៅជិតប៉ៃលិននឹង មីងគេអោយធ្វើតែអន្លង់ស្រូវនឹងមួយទេ?

ខៈ គេអោយធ្វើស្រូវប្រាំង ហើយនឹងយើងដកដំឡូងចឹងទៅ

កៈ ចឹង3ឆ្នាំនឹងគេអោយធ្វើចឹងរហូតណាមីង?

ខៈ គេអោយធ្វើចឹងរហូតនឹង ស្រូវយើងស្ទូងសឹងតែថារាល់ថ្ងៃនឹង

កៈ បាទចឹងមីង?

ខៈ គេថាធ្វើស្រែប្រាំងហាស ច្រូតក៏ធ្លាប់ដែរ ស្ទូងច្រូត ស្ទូងដក
ហើយយើងត្រូវការដកដំឡូងចឹងទៅ ដកដំឡូងអោយយកមកហូបជាមួយបាយចឹងទៅ
ថាគ្មានពេលទំនេរទេនឹងហាស គេអោយយើងធ្វើតែរហូតចឹងទៅណាស់

កៈ បាទមីង! ប៉ុន្តែមីងគេមានអោយផ្លាស់តំបន់ទៅណាទៀតទេមីង?

ខៈ អត់ទេវាផ្លាស់ដែរកាលខ្ញុំនៅចល័ត ខ្ញុំបានធ្វើចល័តរហូតចឹងទៅណា
ហើយយើងដើរតាមចល័តគេអោយយើងដើរតាមចល័តទៅណា
បង្កបង្កើតផលនៅណាគេអោយយើងទៅជួយហើយនឹង

កៈ បាទមីងចឹងហោស?

ខៈ ដល់ពេលដែរត្រលប់មកវិញនឹងធ្វើរាល់ថ្ងៃគេអោយធ្វើស្រែប្រាំងហាស

កៈ បាទមីងចឹងហោស?

ខៈ ធ្វើច្រូតស្ទូងៗៗ
ដកក៏យើងត្រូវការដកដំឡូងចឹងទៅសំរាប់លាយបាយហូបចឹងទៅគ្មានពេលទំនេរទេគេអោយធ្វើតែរហូតចឹងទៅ

កៈ បាទមីង ចុះមីងគេមានអោយផ្លាស់តំបន់ទៅណាទៀតអត់មីង?

ខៈ អត់ទេវាផ្លាស់ដែរកាលពីខ្ញុំនៅចល័តខ្ញុំនៅចល័តរហូតចឹងទៅ
យើងដើរតាមចល័តគេអោយយើងដើរតាមគេ

បង្កបង្កើតផលកន្លែងណាពិបាកគេហៅយើងទៅជួយចឹងទៅ
នឹងជួយគ្នាមួយភ្លែតៗចឹងទៅណា

កៈ អូ៎!គេអោយជួយដែរហោសមីង?

ខៈ ចា៎! ដើរពេលចឹងគេអោយខ្ញុំមកប្រចាំការនៅខាងក្រៅនឹងរហូតដលសន្តិភាពនឹង

កៈ បាទមីង! ចុះសំរាប់គ្រួសាររបស់មីងគេអោយទៅណាដែរទៅមីង មីងទៅតែម្នាក់ឯង
រឺមួយក៏គេអោយទៅទាំងគ្រួសារដែរមីង?

ខៈ គេអោយទៅទាំងអស់គ្នានឹង ពីព្រោះអីគាត់នឹងគេជាអ្នកកាន់ក្របី នឹងកាន់ស្ពឺ
គេអោយគាត់ជាអ្នកភ្ជួររាស់ ហើយយើងជាអ្នកស្ទូងដកអីចឹងទៅ

កៈ បាទមីង ចឹងតើមីងឆ្លងកាត់ការលំបាកមួយនឹងដោយរបៀបណាដែរមីង?

ខៈ អើយក្មួយអើយនិយាយពីការលំបាកកាលណុងយើងវាអត់មានការសប្បាយ
ឧបម៉ាថាយើងដាំបានដំណាំក៏យើងមិនអាចបេះហូបបានទេ ពីព្រោះរបស់គេ
តែបើយើងចង់ហូបទាល់តែយើងសុំគេចឹងទៅណា

កៈ អូ៎!បាទមីង?

ខៈ មើលតែផ្លែផ្កានឹងគេមកមើល តែបាត់នឹងគេថាយើងជាអ្នកបេះ
គេថាយើងលួចរបស់ខ្លួនឯងអីចឹងហាសណា

កៈ អូ៎!ចឹងហោសមីង?

ខៈ ចា៎!យើងដាំៗយើងធ្វើៗហើយគ្មានបានឈប់ដៃទេ
ហើយបើយើងចង់ទៅបេះរហូតអីអត់មានទេ គឺរបបគេបើកប៉ុណ្ណាយើងហូបប៉ុណ្ណឹងឯង

កៈ អូ៎!តាមតែគេអោយនឹងមីង?

ខៈ ចា៎! ហើយពេលយប់ឡើងយើងមិនអាចអង្គុយជជែកគ្នាបានទេ
មានគេចាំឆ្លុះយាមមើលតាមផ្ទះចឹងហាស

កៈ គេធ្វើរាល់ថ្ងៃ?

ខៈ នឹងហើយយើងមិនអាចនិយាយបានទេ
គឺថាអោយតែពេលព្រលប់ឡើងគឺយើងដេកនឹង
បើយើងអង្គុយតែគ្នា2នាក់ចឹងគេចោទយើងថាយើងជាខ្មាំងចឹង
ចង់ពិគ្រោះគ្នាចង់រត់អីចឹងទៅណា

កៈ អ៎ូ!បាទមីងពិបាកដែរ?

ខៈ ចា៎!ចឹងយើងចេះតែតឹងតែង យើងវាពិបាកដែរ

កៈ ចុះពេលដែរដាច់ជំនាន់ពលពត
ហើយក៏ចូលជំនាន់ខ្មែរក្រហមគេអោយមីងទៅណាដែរទៅមីង រឺមួយក៏មីងពេលណុង
មីងធ្វើអីទៅមីង?

ខៈ ដល់ពេលដែរពលពតចេញទៅចឹង យួនចូលមកតាក្មួយ
មានខ្មែរក្រហមមកពីណាដែរក្មួយ គឺពួកយួនចូលមកទេ

កៈ អ៎ូ! យួនហោសមីង?

ខៈ ចា៎!យួនតានឹង

កៈ ប៉ុន្តែកាលពីជំនាន់ឆ្នាំ1983 ដូចជាខ្មែរក្រហមតាហ៊ីមីង?

ខៈ អត់ទេពលពតនឹងហើយខ្មែរក្រហមនឹងហើយក្មួយ

កៈ អ៎ូ! ចឹងទេហោសមីង ខ្ញុំមិនសូវដឹងដែរ?

ខៈ ចា៎!ពេលដែរវាចេញទៅបានយួនចូលមកនឹង ពេលដែរយួនចូលមកនឹង
ក៏គេបានប្រាប់យើងដែរនឹង គេបានប្រាប់យើងមួយខែមុនចឹងទៅណា

កៈ អ៎ូ!គេប្រាប់យើងដែរហោសមីង?

ខៈ នឹងហើយគេប្រាប់ថាយួនចូលមកចឹងទៅណា
គេសំលាប់សូម្បីតែកូននៅក្នុងអង្រឹងក៏គេមិនទុកដែរចឹងទៅណា

កៈ ម៉េចបានគេសំលាប់ចឹងទៅមីង?

ខៈ អត់ទេនយោបាយវាប្រាប់យើងចឹងទៅណា អត់អោយយើងទៅរកយួនចឹងទៅណា
មិនអោយយើងមករំដោះចេញដូចគេចឹងទៅណា

កៈ អ៎ូ!បាទមីងនយោបាយគេហោសមីង?

ខៈ នឹងហើយគេថាដាច់ខាត់មិនអោយយើងចាកចេញពីកន្លែងទេ
ចឹងខ្ញុំខ្លាចដល់ពេលដែរសន្តិភាពនឹង គេបានរត់ទៅអស់រលីងខ្ញុំមិនដឹងទៅខាងណា
កូនរបស់ខ្ញុំអាបងនៅកូនងា
នៅឡើយខ្ញុំនៅបីកូនងាមកដល់មីងរបស់ខ្ញុំនឹងក៏មីងខ្ញុំគាត់ចេះតែសួរទៅណា

កៈ នរណាគេសួរនរណាមីង?

ខៈ គ្នាយើងសួរគ្នានឹងថា ពេលគេមករំដោះនេះតើជាខ្មែររំដោះ រឺមួយក៏យួនជាអ្នករំដោះ គេថាខ្មែរយើងជាអ្នករំដោះទេ ពេលដែរខ្ញុំឆ្លងស្ពានមកខ្ញុំឃើញសុទ្ធតែវៀតណាម ខ្ញុំថាកូនអញ់មិនដឹងយ៉ាងម៉េចទេ

កៈ យើងខ្លាចវាវៃមែនមីង?

ខៈ ចាំខ្លាចដែរនឹងហាស មីងរបស់ខ្ញុំគាត់យកភួយឡើងធំមកគ្រប់លើខ្ញុំនឹង គាត់អោយកូនខ្ញុំបៅដោះខ្ញុំ
មីងរបស់ខ្ញុំគាត់ថាកុំអោយបើអោវាបៅដោះទៅកុំអោយដកចេញ

កៈ ម៉េចចឹងមីង?

ខៈ
មីងគាត់ប្រាប់ថាបើវាយំគេដឹងគេនឹងយកទៅបោះទៅលើទង់រោលនឹងអោយស្លាប់បាត់ឡូវ ហើយនឹងហាស តែការពិតវាមិនមែនទេ វាគ្រាប់តែជានយោបាយចឹងទៅណា

កៈ អ៊ូ!បាទៗមីង តែអត់ធ្វើអីយើងទេ?

ខៈ ថាខ្ញុំភ័យអើយភ័យ
តែដល់ពេលដែរទៅដល់មុខវៀតណាមវាអោយឈប់កន្លែងវានឹងសិនហាស
ចឹងនាំគ្នាឈប់នៅកន្លែងវាចឹងទៅណា
ហើយមីងរបស់ខ្ញុំគាត់យកភួយឡើងធំគ្រប់ខ្ញុំអោយដេកពីរនាក់កូនចឹងទៅណា

កៈ ខ្លាចវាចាប់បានមែនមីង?

ខៈ នឹងហើយខ្លួចដែរនឹងហាស ហើយវាចេះតែអង្គុយសួយើង
និយាយចឹងទៅគាត់សួរមកតាមានកូនងាអតទេ មានកូនតូចអត់
ដល់ពេលចឹងយើងភ័យខ្លាំងហាសណា

កៈ ខ្លាចវាយកទៅបោះចោលណាមីង?

ខៈ នឹងហើយយើងនឹកឃើញភ័យថា យើងមានកូនតូចតែមួយនឹងផងនឹង
បើគេយកកូនរបស់ខ្ញុំយកទៅបោះអោយជាប់នឹងទង់រងនឹង
ជីវិតរបស់ខ្ញុំពិតជាគ្មានអីរស់ទៅមុខទៀតទេ ខ្ញុំយំហើយខ្ញុំនឹកឃើញចឹងហាស

កៈ អ៊ូ!បាទមីងបាទ?

ខ៖ វាចេះតែតាមសួរយើងរហូតនឹង យើងថាអត់មានទេអត់មានកូនតូចទេ
វាថាម៉ែយ៉ាឯងថាអត់មានកូនងា មានកូនងាទេដឹង
ខ្ញុំថាអត់មានទេមីងខ្ញុំថាគាត់ភ័យអើយភ័យ

ក៖ អ៎ូ!ចុះម៉េចទៅមីង?

ខ៖ ហើយវាដាំបាយ វាស្រុះមីងអយយើងស៊ីចឹងទៅណា
វាបានឡើងទៅលើផ្ទះនឹងដល់ពេលម៉ោងណុងខ្ញុំបានឈឺនោមខ្លាំងហើយនឹង
ហើយខ្ញុំបាននឹកឃើញប្រហើរៗភ្ជួយមកបានដាក់មុខកូនហើយខ្ញុំទៅនោមទៅចឹង

ក៖ តែវាបានឃើញទេ?

ខ៖ ហើយវាឆ្លុះពិលចំមុខកូនរបស់ខ្ញុំនឹង ដល់ពេលហើយវាក៏រត់ចុះមកនឹងហាស

ក៖ ចុះវាធ្វើម៉េចទៅចឹង?

ខ៖ វាថាមានកូនងា ថាអត់កូនងា
ខ្ញុំចង់និយាយថាខ្ញុំមានយកកូនងាទៅសំលាប់ណាបើមានកូនងាចឹងទៅ
ខ្ញុំចង់យកកូនងាអោយខ្ញុំដេកនៅក្នុងផ្ទះកុំអោយវាសើម អីចឹងទៅណា បានមីងខ្ញុំគាត់អរ
គាត់ថាកូនអោយមិនមែនទេគេអត់សំលាប់កូនយើងទេកូន
ចឹងទៅខ្ញុំបានបើកភួយអោយវាចឹងទៅ ខ្ញុំបានបែកញើសឡើងជោកខ្លួននឹង

ក៖ អ៎ូ!មីងភ័យហោសមីង?

ខ៖ ខ្ញុំភ័យហាសណា ដល់ពេលចឹងទៅវាមិនមានទេគេមិនបានសំលាប់កូនខ្ញុំទេ

ក៖ ពេលណុងនរណាគេជាអ្នកសួរដែរទៅមីង?

ខ៖ វៀតណាមនឹងឯងជាអ្នកសួរយើងនឹង

ក៖ អ៎ូ!វៀតណាមជាអ្នកសួរយើងហោស?

ខ៖ នឹងហើយវៀតណាមជាអ្នកសួរយើងនឹងឯង

ក៖ ពេលណុងវៀតណាមមកដល់ហើយណមីង?

ខ៖ វាមកជាមួយគ្នាចឹងទៅវាមួយជាមួយខ្មែររំដោះចឹងទៅណា វាបើករថគ្រោះមក
វាស្រែកប្រាប់យើងថាប្រជាពលរដ្ឋខ្មែរ ត្រូវតែក្រោកឈរ ដូចថាអប់អរសោទរគេទៅ
តែបើយើងមិនមែនជាប្រជនខ្មែរយើងក្រាបចុះទៅ

ក៖ ម៉េចចឹងមីង?

ខ៖  គ្រាប់ផ្លោងងាប់ អើយក្មួយអើយដូចគេហាលចឹង វាបានពន្យល់យើងចឹងទៅ ដល់ពេលស្រែទៅយើងនាំគ្នាក្រាបហាស យើងខ្លាចគេផ្លោងមក ហើយវាក៏ផ្លោងមកមែននឹង

ក៖  អូ!ចឹងម៉េចទៅមីង?

ខ៖  នឹងដល់ពេលព្រឹកឡើងចឹងទៅ ក៏ចំទិត្យគូថឡើង ឯក្បាលក៏ក្រាបដល់ដីហើយនឹងហាសគ្រប់តែគ្នានឹងហាស

ក៖  គេធ្វើចឹងធ្វើអីមីង?

ខ៖  គេធ្វើចឹងច្រើនហាសដល់ពេលពួកខ្ញុំទើបតែមកក្រោយគេខ្ញុំអត់ដឹង ដល់ពេលដែរវាចេះតែតាមសួរយើងថាមានកូនងាអត់នឹង ហើយយើងមានកូនងានោះ ចឹងយើងចេះតែភ័យមែនទែនទៅណា ដល់ពេលចឹងវាប្រាប់ថាមិនអីទេគេមិនដែរសំលាប់កូនក្មេងធ្វើអីទៅ

ក៖  អូ!យួនប្រាប់យើងហោសមីង?

ខ៖  ចាំ!យួនប្រាប់យើងនឹង ហើយយើងក៏បើកមុខកូនចេញមក

ក៖  ចុះខ្មែរក្រហមគេទៅណាទៅពេលណុងហាសមីង?

ខ៖  វាក៏រត់ចូលទៅក្នុងព្រៃចឹងទៅ

ក៖  អូ!ចឹងមានន័យថាវៀតណាមវាមកវៃយកហើយណមីង?

ខ៖  ចាំ!គេវៃយករំដោះបណ្តោយហាស គេវៃរំដោះអោយយើងចេញបណ្តោយនឹងហាស ដល់ពេលបានប្រហែលជា2ខែ ដល់ពេល2ខែនឹងយួនដយម្តងនឹង

ក៖  ម៉េចបានយួនថយវិញមីង?

ខ៖  យួនថយលើកទី2ហាសណា យួនថយទៅក្រោយសិននឹង ចឹងទៅគេអោយយើងថយតាម អោយខ្មែរយើងថយតាម តែខ្ញុំថយវាមិនទាន់ ពីព្រោះអីរទេះរបស់ខ្ញុំអត់មានផ្លូវដែក វាមានតែផ្លូវឈើហើយវាបានបាក់ ខ្ញុំទៅអត់ទាន់ក៏ខ្ញុំចូលអាពតម្តងទៀតនឹង

ក៖  អូ!ចូលម្តងទៀត

ខ៖  ចាំ!ចូលម្តងទៀត គេបានកៀរយើងពាក់កណ្តាលនឹងចូលមកក្នុងវិញនឹង ចឹងសំរាប់អ្នកដែរមានប្តីប្រពន្ធអត់មានកូនចឹងទៅ

គេត្រូវការអោយយើងជញ្ជូនស្រូវទៅកប់អោយគេនៅក្បាលក្របីវាធ្វើឃ្លាំងឡើងធំ
វាលាក់ស្រូវទុកនៅណុងហាស
ចឹងមានន័យថាមួយថ្ងៃៗយើងមិនបានធ្វើអីទេគេអោយជញ្ជូនតែស្រូវមួយថ្ងៃមួយជើងៗ
យកទៅកប់ទៅទុកអោយគេនៅនឹងចឹងហាស

ក៖ អូ៎!ចឹងហោសមីង?

ខ៖ ដូចថាគេមានសង្គ្រាមចឹងទៅគេមានកន្លែងស៊ីចឹងទៅណា
ហើយយើងក៏ចូលម្តងទៀតចឹងទៅក៏បាន
វៀតណាមបកមកកៀរម្តងទៀតខ្ញុំក៏បានទៅតាមវៀតណាមចឹងទៅក៏ខ្ញុំរួចទៅ

ក៖ ប៉ុន្តែពេលណុងនៅឆ្នាំណាដែរមីង?

ខ៖ នៅឆ្នាំ មើលតែ3ខែទេ ថាយួនចូលមកបាន3ខែនឹងក៏សំរាកក៏ថយទៅវិញចឹងទៅ
ពេលថយបានមួយខែនឹងក៏គេចូលមករំដោះម្តងទៀតបានគេចូលមករំដោះម្តងទៀតទៅក៏
បានរួចរហូតចឹងទៅចឹងទៅណា

ក៖ អូ៎!បាទមីង?

ខ៖ ពីព្រោះអីយើងនៅជាប់នឹងជាយដែន នៅជាប់ជាមួយនឹងវាចឹងទៅណា

ក៖ បាទមីងគិតថានៅឆ្នាំប៉ុន្មានដែរគិតថាវាសន្តិភាពតែម្តងហាស?

ខ៖ នៅឆ្នាំ1980

ក៖ នៅឆ្នាំ1980ណាមីង?

ខ៖ នឹងហើយសន្តិភាពលែងមានអីហើយនឹង ខ្ញុំមកនៅបាត់ដំបងវិញហើយ
ខ្ញុំដូចថានៅជាមួយមីងអីចឹងទៅណា

ក៖ អូ៎!ប៉ុន្តែពេលណុងគេនៅចាយលុយ រឺមួយក៏គេនៅចាយអីគេដែរមីង?

ខ៖ គេនៅចាយអង្ករ

ក៖ គេនៅចាយអង្ករហោសមីង បើគេចង់លក់ដូរអីគេដូរអង្ករនឹងហោសមីង?

ខ៖ គេដូរអង្ករចឹងទៅ មាននុំនែក គេចាយអង្ករគេចាយមាស

ក៖ លុយកាលពីជំនាន់ណុងថ្ងៃហោសមីង?

ខ៖ អត់ទាន់មានទេ គេមិនទាន់ចាយណា

កៈ ប៉ុន្តែគេអង្ករនឹងរហូត?

ខៈ គេចាប់ផ្តើមចាយនឹងគេចាយ5កាក់
ដល់ពេលគេចាយ5កាក់នឹងបានអង្ករមួយកំប៉ុងនឹងទេ

កៈ អ៊ូ!គេចាយកាក់នៅឡើយទេ?

ខៈ នឹងហើយដូចថា1រៀលចឹងទៅដូរបានអង្ករ2កំប៉ុងចឹងទៅណា

កៈ ចឹងនៅពេលដែរឆ្នាំកៅជាងនឹងមីងលែងមានអីហើយណាមីង?

ខៈ ចា៎!លែងអីហើយនឹង ដូចថាយើងសន្តិភាពមែនទែនហើយណា
ពេលដែរគេចូលមកចឹងទៅវាលែងមានបញ្ហាអីទៀតហើយនឹង

កៈ អ៊ូ!បាទមីង
ចឹងតើមីងគិតថាពេលណាដែរមីងគិតថាជាពេលដែរសប្បាយនៅក្នុងឆាកជីវិតរបស់មីងដែរហោសមីង?

ខៈ ខ្ញុំសប្បាយដូចថារកពេលសប្បាយអត់ឃើញទេនឹងហាស ពីព្រោះអីយើងពិបាកចេះតែគិតពីរឿងអត់ឃ្លានទេ
យើងខំតែរកពីព្រោះអីយើងអត់មានជីវភាពធូធារដូចកាលពីឪពុករបស់យើងនៅអីចឹងទៅណាវាចឹង

កៈ បាទមីងបាទ

ខៈ ចឹងកាលណុងគេប្រមូលយើងអស់ហើយ

កៈ បាទមីង!
ចុះពេលដែរកាលពីនៅក្មេងមីងធ្លាប់មានក្តីស្រម៉ៃថាពេលដែរមីងធំឡើងមីងចង់ធ្វើអីគេដែរទេមីង?

ខៈ ខ្ញុំអត់បានស្រម៉ៃធ្វើអីផងនឹង ពីព្រោះអីខ្ញុំស្រលាញ់តែការចាក់
ខ្ញុំចូលចិត្តតែរឿងចាក់អាវ ចាកកន្សែងអីចឹងទៅ
ដល់ពេលដែរយួនចូលមកដល់យូរបន្តិចមកខ្ញុំចេះធ្វើកណ្តាប
អាកណ្តាបស្លឹកត្នោតយើងចឹងទៅណា

កៈ អ៊ូ!មីងចេះយកស្លឹកត្នោត យកមកធ្វើជាកណ្តាបហោសមីង
ខៈ នឹងបានជីវភាពរបស់ខ្ញុំបានរស់នៅពេលដែរយួនចូលមកយើងទៅរកអីអត់បានហាស

កៈ អូ៎!បាទមីង
ខៈ តិចទៅគេផ្លោងខាងនេះ តិចទៅគេផ្លោងខាងនោះ ខ្ញុំមិនមានអីគេទេខ្ញុំអោយប្ដីរបស់ខ្ញុំដើរកាប់ស្លឹកត្នោតមកដើម្បីយកមកធ្វើ ហើយយកទៅលលុយលក់មួយបានតែ300លុយខ្មែរទេ

កៈ បាទមីងបាទ?

ខៈ ប៉ុណ្ណឹង កាលណុងថ្នាំលាបវាថោកហាសចឹងខ្ញុំធ្វើខ្លួនឯងនឹង ពេលយប់ចឹងទៅបាន300កណ្ដាបអីចឹងដើម្បីយកទៅលក់អីចឹងទៅណា ក៏បានទិញអង្ករហូបអីចឹងទៅណា

កៈ ចឹងជាចុងក្រោយបើចង់អោយមីងផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយៗ តើមីងចង់ផ្ដែផ្ដាំអីទៅពួកគាត់ដែរមីង?

ខៈ ចង់ផ្ដែផ្ដាំថាអោយខំរៀនសូត្រ ហើយនឹងខំយកចិត្តទុកដាក់បីការងារ ដូចថាកុំអោយយើងប្រព្រឹត្តនូវអំពើមិនសមហេតុផលអោយសោះនឹងហាស

កៈ បាទមីងមានអីផ្សេងទៀតទេមីង?

ខៈ
ជាពិសេសគ្រឿងញៀនអីនឹងសុំអោយគេចវេសចេញទៅកុំអោយនេះមិនមែនជារបរបានប្រយោជន៍ទេនឹងហោស

កៈ បាទត្រូវហើយមីង?

ខៈ ចឹងយើងជាកូនខ្មែរយើងត្រូវយកចិត្តទុកដាក់ រៀនសូត្រពីខ្មែរយើងមកបានវាល្អ កុំយកអីពីសាសន៍គេយកមកទុកក្នុងខ្លួនយើងមកវាមិនល្អទេនឹងហោស

កៈ បាទមីងបាទចឹងមានអីផ្សេងទៀតទេមីង?
ខៈ ចា៎!អស់ហើយនឹង

កៈ
បាទមីងជាចុងក្រោយខ្ញុំអរគុណច្រើនមីងដែរបានផ្ដល់ពេលវេលាដែរបានរក្សាពេលវេលាសំភាសន៍ដែរទាក់ទងពីប្រវត្តិរបស់មីងចឹងហាសមីង

ខៈ ចា៎!នឹងហើយក្មួយ

កៈ បាទមីងបាទអរគុណច្រើនមីង៕៕៕